# ព្រះរាជាណាចក្រកម្ពុជា

# ច្បាប់ ស្តីពី អ៊ី-ពាណិជ្ជកម្ម

**ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ**

មាត្រា ១ : គោលបំណង

មាត្រា ២ : ដែនអនុវត្តន៍

មាត្រា ៣ : ការប្រែប្រួលតាមការព្រមព្រៀង

មាត្រា ៤ : និយមន័យ

**ផ្នែក ២ សុពលភាពនៃសារទិន្នន័យ និងសារអេឡិចត្រូនិក**

មាត្រា ៥ : ការទទួលស្គាល់តាមផ្លូវច្បាប់នៃសារទិន្នន័យ និងសារអេឡិចត្រូនិក

មាត្រា ៦ : លក្ខខណ្ឌលាយលក្ខណ៍អក្សរ

មាត្រា ៧ : លក្ខខណ្ឌហត្ថលេខា

មាត្រា ៨ : លក្ខខណ្ឌសំណៅដើម

មាត្រា ៩ : លក្ខខណ្ឌនៃការរក្សាទុកកំនត់ត្រា

មាត្រា ១០ : លក្ខខណ្ឌភស្តុតាង

មាត្រា ១១ : ការបង្កើតកិច្ចសន្យា

មាត្រា ១២ : សេចក្តីប្រកាស និងសេចក្តីថ្លែងដ៏ទៃទៀត

**ផ្នែក ៣ នីតិវិធីនៃទំនាក់ទំនង**

មាត្រា ១៣ : ការសន្មត់

មាត្រា ១៤ : ពេលវេលា និងទីកន្លែងនៃការបញ្ជូន និងការទទួល នូវសារទិន្នន័យ

**ផ្នែក ៤ អ្នកផ្តល់សេវាវិញ្ញាបនកម្ម**

មាត្រា ១៥ : ការចេញបទបញ្ជា

**ផ្នែក ៥ កិច្ចរដ្ឋាភិបាល និងចម្លងការ**

មាត្រា ១៦ : ការទទួលយកសារទិន្នន័យ

**ផ្នែក ៦ បទល្មើសប្រឆាំងនឹង ការសំងាត់ បូរណភាព ភាពអាចរកបាន នៃប្រព័ន្ធព័ត៌មាន និងទិន្នន័យកុំព្យូទ័រ**

មាត្រា ១៧ : ការចូលខុសច្បាប់

មាត្រា ១៨ : ការរាំងខុសច្បាប់

មាត្រា ១៩ : ការជ្រៀតជ្រែកចូលទិន្នន័យ



Downloaded from http://www.khmerlaws.com

**មាត្រា ២០ : ការជ្រៀតជ្រែកចូលប្រព័ន្ធ**

**មាត្រា ២១ : ការក្លែងបន្លំលើទិន្នន័យកុំព្យូទ័រ**

**មាត្រា ២២ : ការបន្លំលើកុំព្យូទ័រ**

**មាត្រា ២៣ : ការញុះញង់ ការជួយ ការជំរុញលើកទឹកចិត្ត ការសមគំនិត ឬការប៉ុនប៉ង**

**មាត្រា ២៤ : ទោសប្បញ្ញត្តិ**

## ផ្នែកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ : គោលបំណង**

ច្បាប់នេះត្រូវបានរៀបចំឡើង ដើម្បីសំរេចបានទូវគោលដៅ និងត្រូវបានបកស្រាយ ដោយអនុលោមតាមគោលបំណងដូចតទៅ :

(ក) សម្រួលដល់ អ៊ី-ពាណិជ្ជកម្មក្នុងស្រុក និងអន្តរជាតិ ដោយការលុបបំបាត់របាំងច្បាប់ និងបង្កើតភាពប្រាកដប្រជាផ្លូវច្បាប់

(ខ) ជំរុញលើកទឹកចិត្ត ការប្រើប្រាស់ទំរង់ អ៊ី-ពាណិជ្ជកម្មដែលអាចជឿទុកចិត្តបាន

(គ) សម្រួលដល់ ការរៀបចំឯកសារតាមប្រព័ន្ធអេឡិចត្រូនិក ជាមួយរដ្ឋាភិបាល និងលើកស្ទួយការផ្ដល់សេវាកម្មប្រកបដោយប្រសិទ្ធិភាពរបស់រដ្ឋាភិបាល តាមមធ្យោបាយនៃ ទំរង់ដែលអាចជឿទុកចិត្តបាន នៃសារអេឡិចត្រូនិក

(ឃ) លើកស្ទួយ ការជឿទុកចិត្តរបស់សាធារណជនលើ យថាភាព បូរណភាព និងភាពអាចជឿទុកចិត្តបាន នៃសារទិន្នន័យ និងសារអេឡិចត្រូនិក

(ង) ហាមឃាត់ ការប្រព្រឹត្តិអំពើដែលបង្កព្យសនកម្មលើ ទិន្នន័យកុំព្យូទ័រ និងប្រព័ន្ធព័ត៌មាន ។

**មាត្រា ២ : ដែនអនុវត្តន៍**

១. បទប្បញ្ញត្តិដែលមានចែងនៅក្នុងផ្នែកទី២ ដល់ផ្នែកទី៥ នៃច្បាប់នេះ អនុវត្តចំពោះគ្រប់ច្បាប់រដ្ឋប្បវេណី និងច្បាប់ពាណិជ្ជកម្ម និងប្រតិបត្តិការនានា។ លើកលែងតែ ច្បាប់ និងប្រតិបត្តិការ ទាំងឡាយណាដែលត្រូវបានលើកលែងក្រោម លក្ខខណ្ឌនៃច្បាប់នេះ ឬដោយបទប្បញ្ញាតរបស់រដ្ឋាភិបាល ។

២. គ្មានបទប្បញ្ញត្តិណាដែលមានចែងនៅក្នុងផ្នែកទី២ ដល់ផ្នែកទី៥ នៃច្បាប់នេះ អាចប៉ះពាល់ដល់ការអនុវត្តន៍ នៃវិធានគតិយុត្តណាមួយដែលទាមទារឱ្យគូភាគី បង្ហាញអត្តសញ្ញាណ ទីកន្លែងប្រកបអាជីវកម្ម របស់ពួកគេ ឬព័ត៌មានផ្សេងទៀត ឬដែល លើកលែងភាគីមួយ ឱ្យរួចផុតពីផលវិបាកគតិយុត្តនៃការបង្កើតសេចក្ដីថ្លែង មិនពិតប្រាកដ ឬមិនត្រឹមត្រូវ នៅក្នុងបញ្ហានេះ ។

៣. បទប្បញ្ញត្តិដែលមានចែងនៅក្នុងផ្នែកទី២ ដល់ផ្នែកទី៤ នៃច្បាប់នេះ អនុវត្តចំពោះកិច្ច និងចម្លងការ ដែលបំពេញដោយ ឬជាមួយ រដ្ឋាភិបាល អនុលោមតាម ផ្នែកទី៥ នៃច្បាប់ដដែលនេះ។



Downloaded from http://www.khmerlaws.com

**មាត្រា ៣ : ការប្រែប្រួលតាមការព្រមព្រៀង**

បទប្បញ្ញត្តិនៃ ផ្នែកទី២ និងផ្នែកទី៣ អាចប្រែប្រួលដោយសារ ការព្រមព្រៀងរវាងគូភាគីលើ ការបង្កើត ការផ្ញើរ ការរក្សាទុក ឬលើដំណើរការសារទិន្នន័យ ផ្សេងទៀត លើកលែងតែមានការចែងផ្សេងពីនេះ ។

**មាត្រា ៤ : និយមន័យ**

និយមន័យនៃពាក្យដែលប្រើនៅក្នុងច្បាប់នេះ ត្រូវបានកំនត់ដូចតទៅ :

**"អ្នកទទួល"** នៃសារអេឡិចត្រូនិកមួយ មានន័យថា ជាភាគីដែល អ្នកផ្ញើរមានបំនងឱ្យបានទទួលនូវសារអេឡិចត្រូនិក តែមិនរួមបញ្ចូលទាំងអ្នក ដែលធ្វើសកម្មភាពជាអន្តការី ចំពោះសារអេឡិចត្រូនិកនោះទេ ។

**"ប្រព័ន្ធសារស្វ័យប្រវត្តិ"** មានន័យថា ជាកម្មវិធីកុំព្យូទ័រ ឬជាមធ្យោបាយអេឡិចត្រូនិក ឬជាមធ្យោបាយស្វ័យប្រវត្តិដ៏ទៃទៀត ដែលប្រើសំរាប់ផ្តួចផ្តើមសកម្មភាពមួយ ឬក៏ឆ្លើយតប ទាំងស្រុង ឬដោយផ្នែក ទៅនឹង សារទិន្នន័យ ឬសកម្មភាពនានា ដោយគ្មានការត្រួតពិនិត្យ ឬអន្តរាគមន៏របស់មនុស្ស រៀងរាល់ពេលដែលសកម្មភាពមួយត្រូវបានផ្តួចផ្តើម ឬក៏ចម្លើយមួយត្រូវបានបង្កើត ដោយប្រព័ន្ធនេះ ។

**"អ្នកផ្តល់សេវាវិញ្ញាបនកម្ម"** មានន័យថា ជាបុគ្គលដែលចេញវិញ្ញាបនបត្រ និងព្រមទាំងអាចផ្តល់សេវាកម្មនានាដ៏ទៃទៀត ទាកទងទៅនឹង ហត្ថលេខាអេឡិចត្រូនិក ។

**"ទិន្នន័យកុំព្យូទ័រ"** មានន័យថា ជាការបង្ហាញហេតុការណ៏ ព័តិមាន ឬវត្ថុដែលគេគិតឃើញ ក្នុងទំរង់ដែលសមរម្យសំរាប់ដំណើរការនៅក្នុងប្រព័ន្ធព័តិមាន ដោយរួមបញ្ចូលទាំង កម្មវិធីដែលសមប្រកបសំរាប់បង្កើតប្រព័ន្ធព័តិមាន ដើម្បីបង្កើតឱ្យមានដំណើរការមួយ ។

**"សារទិន្នន័យ"** មានន័យថា ជាព័តិមានដែលត្រូវបានបង្កើត ផ្ញើរ ទទួល ឬរក្សាទុក ដោយមធ្យោបាយអេឡិចត្រូនិក ម៉ាញេទិច អុបទិច ឬដោយមធ្យោបាយស្រដៀងនេះ ។

**"សារអេឡិចត្រូនិក"** មានន័យថា ជាសារណាមួយដែលគូភាគី បង្កើតឡើងដោយមធ្យោបាយនៃ សារទិន្នន័យ ។

**"ហត្ថលេខាអេឡិចត្រូនិក"** មានន័យថា ជាទិន្នន័យក្នុងទំរង់អេឡិចត្រូនិក នៅក្នុង ចារិកទៅនឹង ឬបើនិយាយឱ្យចំ ដែលចងភ្ជាប់ជាមួយសារទិន្នន័យដែលអាចត្រូវបានប្រើដើម្បីកំនតទំនាក់ទំនងរវាងហត្ថលេខី និងសារទិន្នន័យ និងដើម្បីបញ្ជាក់ពី ការយល់ព្រមរបស់ហត្ថលេខី លើព័តិមានដែលមាននៅក្នុង សារទិន្នន័យ ។

**"បណ្តាញព័តិមាន"** មានន័យថា ជាឧបករណ៏អ្វីមួយ ឬជាឧបករណ៏មួយចំនួនដែលតភ្ជាប់គ្នា ឬដែលទាក់ទងគ្នា សំរាប់ការបង្កើត ការផ្ញើរ ការទទួល ការរក្សាទុក ឬសំរាប់ដំណើរការទិន្នន័យកុំព្យូទ័រផ្សេងទៀត ដោយរួមទាំង សារទិន្នន័យផងដែរ ។



Downloaded from http://www.khmerlaws.com

**"អ្នកផ្ញើរ"** នៃសារអេឡិចត្រូនិកមួយ មានន័យថា ជាភាគី ដែលបានផ្ញើរ ឬបង្កើត សារអេឡិចត្រូនិក មុនការរក្សាទុកវា ឬក្នុងនាមនៃភាគីនេះ សារអេឡិចត្រូនិក ត្រូវបានផ្ញើរ ឬបង្កើត មុនការរក្សាទុក តែមិនរួមបញ្ចូលទាំងអ្នកដែលធ្វើសកម្មភាពជាអន្តការី ចំពោះសារអេឡិចត្រូនិកនោះទេ ។

## ផ្នែក ២
## សុពលភាពនៃសារទិន្នន័យ និងសារអេឡិចត្រូនិក

### មាត្រា ៥ : ការទទួលស្គាល់តាមផ្លូវច្បាប់នៃសារទិន្នន័យ និងសារអេឡិចត្រូនិក

១. ព័ត៌មានមួយ មិនអាចត្រូវបានគេបដិសេធពី អានុភាពគតិយុត្ត សុពលភាពគតិយុត្ត ភាពអាចអនុវត្តបានរបស់វា ដោយសារតែមូលហេតុតែមួយដែលថា វាឋិតក្នុងទំរង់ជាសារទិន្នន័យ នោះទេ ។

២. សារមួយ ឬកិច្ចសន្យាមួយ មិនអាចត្រូវបានគេបដិសេធពី អានុភាពគតិយុត្ត សុពលភាពគតិយុត្ត ភាពអាចអនុវត្តបានរបស់វា ដោយសារតែមូលហេតុតែមួយដែលថា វាឋិតក្នុងទំរង់ជាសារអេឡិចត្រូនិកនោះទេ ។

### មាត្រា ៦ : លក្ខខណ្ឌលាយលក្ខណ៍អក្សរ

១. ក្នុងករណីដែលច្បាប់តម្រូវឱ្យមាន ព័ត៌មានជាលាយលក្ខ័អក្សរ លក្ខខណ្ឌនោះអាចត្រូវបំពេញដោយសារទិន្នន័យ ប្រសិនបើ ព័ត៌មានដែលមានក្នុងនោះ អាចឱ្យគេអានបាន ដើម្បីនឹងអាចប្រើប្រាស់សំរាប់ជាឯកសារយោងនៅពេលក្រោយ ។

២. កឋាខ័ណ្ឌ១.នេះ អនុវត្ត មិនថា លក្ខខណ្ឌដែលមានក្នុងនោះ មានលក្ខណៈជាកាតព្វកិច្ច ឬក៏ច្បាប់គ្រាន់តែចែងពីផលវិបាកចំពោះព័ត៌មានដែលមិនជាលាយលក្ខ័អក្សរ នោះទេ ។

៣. បទប្បញ្ញត្តិនៃមាត្រានេះ មិនអនុវត្តចំពោះ លក្ខខណ្ឌទាំងឡាយដែលតម្រូវឱ្យព័ត៌មានជាលាយលក្ខ័អក្សរ ដូចខាងក្រោមនេះ :

(...)

### មាត្រា ៧ : លក្ខខណ្ឌហត្ថលេខា

១. ក្នុងករណីដែល ច្បាប់តម្រូវឱ្យមានហត្ថលេខារបស់បុគ្គលម្នាក់ លក្ខខណ្ឌនោះអាចត្រូវបំពេញដោយសារទិន្នន័យ ប្រសិនបើ ហត្ថលេខាអេឡិចត្រូនិក ដែលប្រើនោះ អាចឱ្យជឿទុកចិត្តបាន និងសមស្របសំរាប់គោលបំនង ដែលសារទិន្នន័យត្រូវបានគេបង្កើត ឬបញ្ជូនឱ្យ ក្នុងគ្រប់កាលទេសៈទាំងអស់ រួមទាំង ការព្រមព្រៀងណាមួយ ។

២. កឋាខ័ណ្ឌ១.នេះ អនុវត្ត មិនថា លក្ខខណ្ឌដែលមានក្នុងនោះ មានលក្ខណៈជាកាតព្វកិច្ច ឬក៏ច្បាប់គ្រាន់តែចែងពីផលវិបាកសំរាប់អវត្តមាននៃហត្ថលេខាអេឡិចត្រូនិក នោះទេ ។



Downloaded from http://www.khmerlaws.com

៣. ហត្ថលេខាអេឡិចត្រូនិកត្រូវបានសន្មត់ថាអាចជឿទុកចិត្តបាន សំរាប់គោលបំណងក្នុងការបំពេញលក្ខខណ្ឌដែលបាន យោងនៅក្នុង កឋាខ័ណ្ឌ ១.ខាងលើប្រសិនបើ :

(ក) វាជាចំនងតែមួយគត់ដែលចងភ្ជាប់ ហត្ថលេខី

(ខ) វាមានលទ្ធភាពក្នុងការកំណត់អត្តសញ្ញាណឱ្យហត្ថលេខី

(គ) វាបង្កើតមធ្យោបាយប្រើប្រាស់ ដែលហត្ថលេខីអាចរក្សាឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួនតែម្នាក់ ហើយ

(ឃ) វាចងភ្ជាប់ទៅនឹងទិន្នន័យដែលវាមានទំនាក់ទំនងក្នុងរបៀបមួយដែលការផ្លាស់ប្ដូរទិន្នន័យនៅពេលក្រោយ អាចឱ្យគេដឹងបាន ។

៤. កឋាខ័ណ្ឌ៣.នេះ មិនកំរិតពីសមត្ថភាពរបស់បុគ្គលណាមួយឡើយ:

(ក) ក្នុងការបង្កើតភាពអាចជឿទុកចិត្តបាននៃហត្ថលេខាអេឡិចត្រូនិក តាមផ្លូវផ្សេងណាមួយក្នុង គោល- បំណង បំពេញលក្ខខណ្ឌដែលបានយោងនៅក្នុងកឋាខ័ណ្ឌ១.ខាងលើ ឬ

(ខ) ក្នុងការផ្ដល់ភស្តុតាង ពីភាពមិនអាចជឿទុកចិត្តបាន នៃហត្ថលេខាអេឡិចត្រូនិក ។

៥. បទប្បញ្ញត្តិនៃមាត្រានេះ មិនអនុវត្តចំពោះលក្ខខណ្ឌសំរាប់ហត្ថលេខា ដែលមានដូចខាងក្រោម :

(...)

**មាត្រា ៨ : លក្ខខណ្ឌសំណៅដើម**

១. ក្នុងករណីដែលច្បាប់តម្រូវឱ្យ បង្ហាញ ឬរក្សាព័ត៌មានក្នុងទំរង់ជាសំណៅដើមរបស់វា លក្ខខណ្ឌនោះអាចត្រូវបាន បំពេញដោយសារទិន្នន័យ ប្រសិនបើ :

(ក) មានការធានាអះអាង ដែលអាចជឿទុកចិត្តបាន ចំពោះបូរណភាពនៃព័ត៌មាន ចាប់តាំងពីពេលដែលវា ត្រូវបានបង្កើត ក្នុងទំរង់លើកដំបូង រហូតដល់ ទំរង់ចុងក្រោយរបស់វា ជាសារទិន្នន័យ ឬអ្វីផ្សេងពីនេះ ។

(ខ) នៅពេលដែលមានការតម្រូវឱ្យបង្ហាញព័ត៌មាន ព័ត៌មាននោះអាចបង្ហាញទៅកាន់បុគ្គលដែលវាត្រូវ បង្ហាញ ។

២. បទប្បញ្ញត្តិនៃកឋាខ័ណ្ឌ១.នេះ អនុវត្ត មិនថា លក្ខខណ្ឌដែលមានក្នុងនោះ មានលក្ខណៈជាកាតព្វកិច្ច ឬក៏ច្បាប់ គ្រាន់តែចែង ពីផលវិបាកសំរាប់ព័ត៌មានដែលមិនត្រូវបានបង្ហាញ ឬរក្សា ក្នុងទំរង់ជាសំណៅដើមរបស់វា ។

៣. សំរាប់គោលបំណង នៃ កឋាខ័ណ្ឌ១.(ក) ខាងលើនេះ :

(ក) លក្ខណៈវិនិច្ឆ័យសំរាប់វាយតំលៃពីបូរណភាព គឺថា តើព័ត៌មាន នៅពេញលេញ និងមិនមានការកែប្រែ ក្រៅអំពី ចំណារបន្ថែម ឬការផ្លាស់ប្ដូរណាមួយ ក្នុងដំណើរការជាធម្មតានៃការបញ្ជូន ការរក្សារទុក និង ការបង្ហាញ ហើយ

(ខ) ស្តង់ដារនៃ ភាពអាចជឿទុកចិត្តបានដែលបានតម្រូវ ត្រូវវាយតំលៃតាមរបៀប នៃគោលបំណងដែលព័ត៌ ត្រូវបង្កើត និង ក្នុងគ្រប់កាលទេសៈដែលពាក់ពាន់ទាំងអស់ ។



Downloaded from http://www.khmerlaws.com

**មាត្រា ៩ : លក្ខខណ្ឌនៃការរក្សាទុកកំនត់ត្រា**

១. ក្នុងករណីដែលច្បាប់តម្រូវឱ្យមានការរក្សាទុកឯកសារ កំនត់ត្រា ឬព័ត៌មាន ជាក់លាក់ណាមួយ លក្ខខណ្ឌនោះអាចត្រូវបានបំពេញដោយ ការរក្សាទុកសារទិន្នន័យ ប្រសិនបើលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :

(ក) ព័ត៌មានដែលមានក្នុងនោះ អាចរកបាន និង អាចប្រើប្រាស់បានសំរាប់សេចក្តីត្រូវការនៅពេលខាងមុខ និង

(ខ) សារទិន្នន័យ ត្រូវរក្សាទុកក្នុងទំហំដូចពេលដែលវាត្រូវបានគេបង្កើត ផ្ញើរ ឬទទួល ឬក៏ក្នុងទំហំដែលអាចបង្ហាញបានថា តំណាងឱ្យយ៉ាងត្រឹមត្រូវ នូវព័ត៌មានដែលបានបង្កើត ផ្ញើរ ឬទទួលនោះ និង

(គ) ព័ត៌មាននោះ ប្រសិនបើមាន ត្រូវរក្សាក្នុងលក្ខណៈដែលអាចកំនត់ពីប្រភព និងគោលដៅ នៃសារទិន្នន័យ និងកាលបរិច្ឆេទ ដែលវាត្រូវបានផ្ញើរ ឬទទួល ។

២. កាតព្វកិច្ចក្នុងការរក្សា ឯកសារ កំនត់ត្រា ឬក៏ព័ត៌មាន ដែលមានចែងក្នុងកថាខ័ណ្ឌ១.ខាងលើនេះ មិនគ្របដណ្តប់លើព័ត៌មានទាំងឡាយណា ដែលគេមានគោលបំណងត្រឹមតែសំរាប់ផ្ញើរ ឬទទួលសារនោះទេ ។

**មាត្រា ១០ : លក្ខខណ្ឌភស្តុតាង**

១. ចំពោះគ្រប់នីតិវិធីទាំងអស់ គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងការអនុវត្តន៏វិធានភស្តុតាងក្រោម (...) មិនត្រូវយកមកអនុវត្ត ដើម្បីច្រានចោល ភាពអាចទទួលយកបាននៃសារទិន្នន័យ ក្នុងការបង្ហាញភស្តុតាង :

(ក) ដោយសារតែមូលហេតុថា វាជាសារទិន្នន័យ ឬ

(ខ) ដោយសារតែមូលហេតុថា វាមិនឋិតក្នុងទំរង់ដើមរបស់វា ប្រសិនបើវាជាភស្តុតាងដ៏ប្រសើរជាងគេ ដែលបុគ្គលបានរំពឹងទុក ។

២. ព័ត៌មានក្នុងទំរង់ជាសារទិន្នន័យ ត្រូវបានទទួលទំងន់ភស្តុតាងសមស្របមួយ ។ ក្នុងការវាយតំលៃពីទំងន់ភស្តុតាងនៃសារទិន្នន័យ ត្រូវពិនិត្យពិចារណាទៅលើភាពអាចជឿទុកចិត្តបាននៃរបៀបដែលសារទិន្នន័យមួយ ត្រូវបានបង្កើត រក្សាទុក ឬបញ្ជូន ទៅលើភាពអាចជឿទុកចិត្តបាននៃរបៀបរក្សាបូរណភាពរបស់ព័ត៌មាន ទៅលើរបៀបក្នុងការកំនត់អត្តសញ្ញាណនៃអ្នកផ្ញើរព័ត៌មាននោះ និងទៅលើកត្តាផ្សេងៗទៀតដែលពាក់ព័ន្ធ ។

**មាត្រា ១១ : ការបង្កើតកិច្ចសន្យា**

១. ក្នុងបរិបទនៃការបង្កើតកិច្ចសន្យា លើកលែងតែមានការព្រមព្រៀងផ្សេងទៀតរវាងគូភាគី សំនើ និងស្ទីការលើសំនើអាចធ្វើឡើង តាមមធ្យោបាយនៃ សារទិន្នន័យ ។ នៅពេលដែលសារទិន្នន័យត្រូវបានប្រើ ក្នុងការបង្កើតកិច្ចសន្យា កិច្ចសន្យានោះ វាមិនត្រូវបានបដិសេធពី សុពលភាព ឬភាពអាចអនុវត្តបានរបស់វា ដោយសារតែសារទិន្នន័យត្រូវបានប្រើសំរាប់ ការបង្កើតកិច្ចសន្យានោះ ។

២. សំនើចុះកិច្ចសន្យាដែលធ្វើឡើងតាមសារអេឡិចត្រូនិកមួយ ឬច្រើន ដែលមិនសំដៅជាពិសេសចំពោះភាគីមួយ ឬច្រើន ទេនោះ តែបើកចំហជាទូទៅចំពោះភាគីនានាដែលមានប្រើប្រព័ន្ធព័ត៌មាន ដោយរួមបញ្ចូលទាំងសំនើនានាដែលប្រើប្រាស់ប្រតិបត្តិការអន្តរកម្ម ក្នុងការបញ្ជាទិញតាមប្រព័ន្ធព័ត៌មាននោះ ត្រូវបានគេចាត់ទុកជា ការអញ្ជើញ



Downloaded from http://www.khmerlaws.com

ឱ្យធ្វើសំនើ លើកលែងតែមានការបញ្ជាក់យ៉ាងច្បាស់របស់ភាគីធ្វើសំនើ ពីគោលបំណងបង្កើតចំណងគតិយុត្ត ករណីដែលមានស្ទីការលើសំនើនោះ ។

៣. កិច្ចសន្យាដែលបង្កើតដោយ អន្តរកម្មនៃប្រព័ន្ធសារស្វ័យប្រវត្តិមួយ មិនត្រូវបានគេបដិសេធពី សុពលភាព ឬភាពអាចអនុវត្តបានរបស់វា ដោយសារតែ គ្មានរូបវន្តបុគ្គលត្រួតពិនិត្យ លើសកម្មភាពនិមួយៗដែល បំពេញដោយប្រព័ន្ធ ឬកិច្ចសន្យាដែលបង្កើតនោះ ។

៤. គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងច្បាប់នេះ អាចប៉ះពាល់ ដល់ការអនុវត្តនីតិវិធានគតិយុត្តណាដែលតម្រូវឱ្យភាគីមួយដែលបានចរចាលើលក្ខខណ្ឌមួយចំនួន ឬទាំងអស់នៃកិច្ចសន្យាមួយតាមការផ្លាស់ប្តូរគ្នានូវសារអេឡិចត្រូនិក ប្រគល់ឱ្យភាគីម្ខាងទៀតនូវសារអេឡិចត្រូនិកទាំងនោះក្នុងទំរង់ពិសេសមួយ ឬក៏ដល់ការអនុវត្តនីតិវិធានគតិយុត្តដែលលើកលែងភាគីមួយឱ្យរួចផុត ពីផលវិបាកគតិយុត្តបណ្តាលមកពីការមិនបំពេញកាតព្វកិច្ច ។

៥. បទប្បញ្ញត្តិនៃមាត្រានេះ មិនអនុវត្តចំពោះប្រភេទកិច្ចសន្យាមួយចំនួនដូចតទៅ :

(...)

**មាត្រា ១២ : សេចក្តីប្រកាស និងសេចក្តីថ្លែងដទៃទៀត**

ក្នុងទំនាក់ទំនងរវាង អ្នកផ្ញើរ និង អ្នកទទួលសារទិន្នន័យ ការសំដែងឆន្ទៈ ឬសេចក្តីថ្លែងផ្សេងទៀត មិនត្រូវបានបដិសេធពីអានុភាពគតិយុត្ត សុពលភាពគតិយុត្ត ឬភាពអាចអនុវត្តបានតាមផ្លូវច្បាប់ ដោយសារតែវាស្ថិតក្នុងទំរង់ជាសារទិន្នន័យនោះទេ ។

## ផ្នែក ៣
## នីតិវិធីនៃទំនាក់ទំនង

**មាត្រា ១៣ : ការសន្មត់**

១. សារទិន្នន័យមួយ សន្មត់ថាជារបស់អ្នកផ្ញើរ ប្រសិនបើវាត្រូវបានផ្ញើរ ដោយអ្នកផ្ញើរ ដោយផ្ទាល់ ។

២. ក្នុងទំនាក់ទំនងរវាងអ្នកផ្ញើរ និងអ្នកទទួល សារទិន្នន័យមួយត្រូវចាត់ទុកថាជារបស់អ្នកផ្ញើរ ប្រសិនបើវាត្រូវបានផ្ញើរ :

(ក) ដោយបុគ្គលដែលមានសមត្ថកិច្ច ធ្វើសកម្មភាពក្នុងនាមនៃអ្នកផ្ញើរ ទាក់ទងនឹង សារទិន្នន័យនោះ ឬ

(ខ) ដោយប្រព័ន្ធព័តិមាន ដែលត្រូវបានបញ្ចូលកម្មវិធីដោយ ឬក្នុងនាមនៃអ្នកផ្ញើរ ឱ្យដំនើរការដោយស្វ័យប្រវត្តិ ។

៣. ក្នុងទំនាក់ទំនងរវាង អ្នកផ្ញើរ និងអ្នកទទួល អ្នកទទួលមានសិទ្ធិចាត់ទុកថា សារទិន្នន័យជារបស់អ្នកផ្ញើរ ហើយធ្វើសកម្មភាពដោយផ្អែកលើ ការសន្មត់នោះ ប្រសិនបើ :

(ក) ដើម្បីរកឱ្យឃើញថាសារទិន្នន័យពិតជារបស់អ្នកផ្ញើរ អ្នកទទួលបានអនុវត្តយ៉ាងត្រឹមត្រូវនូវនីតិវិធីដែលបានព្រមព្រៀងជាមុនជាមួយអ្នកផ្ញើរ សំរាប់គោលបំណងនោះ ឬ



Downloaded from http://www.khmerlaws.com

(ខ) សារទិន្នន័យដែលអ្នកទទួលបានទទួល ចេញពីសកម្មភាពរបស់បុគ្គលដែលមានទំនាក់ទំនងជាមួយ អ្នកផ្ញើរ ឬជាមួយភ្នាក់ងាររបស់អ្នកផ្ញើរ ដែលអាចឱ្យបុគ្គលនោះដឹងពីរបៀបរបស់អ្នកផ្ញើរ ក្នុងការកំនត់សំគាល់សារទិន្នន័យមួយ ថាជារបស់ខ្លួន ។

៤. បទប្បញ្ញត្តិក្នុងកថាខណ្ឌ៣ មិនត្រូវអនុវត្ត :

(ក) ចាប់ពីពេលដែលអ្នកទទួល បានទទួលដំណឹងពីអ្នកផ្ញើរថាសារទិន្នន័យនោះមិនមែនជារបស់ខ្លួនទេ ហើយអ្នទទួលមានពេលវេលាគ្រប់គ្រាន់ ដើម្បីធ្វើសកម្មភាពសម្រេបតាមដំណឹងនោះ ឬ

(ខ) ក្នុងករណីដូចបានចែងក្នុងកថាខណ្ឌ ៣.(ខ) នៅគ្រប់ពេលទាំងអស់ដែល អ្នកទទួលបានដឹង ឬគួរតែបានដឹង តាមការដែលបានយកចិត្តទុកដាក់ក្នុងកិរិតសមរម្យ ឬបានប្រើនីតិវិធីព្រមព្រៀងណាមួយ ថាសារអេឡិចត្រូនិក មិនមែនជារបស់អ្នកផ្ញើរ ។

៥. ក្នុងករណីដែលសារទិន្នន័យជារបស់អ្នកផ្ញើរ ឬត្រូវបានចាត់ទុកថាជារបស់អ្នកផ្ញើរ ឬអ្នកទទួលមានសិទ្ធិធ្វើសកម្មភាពអនុលោមតាមការសន្មត់នោះ ពេលនោះ ក្នុងទំនាកទំនងរវាងអ្នកផ្ញើរ និងអ្នកទទួល អ្នកទទួលមានសិទ្ធិចាត់ទុកថាសារទិន្នន័យត្រូវបានទទួល និងថាវាជាអ្វីដែលអ្នកផ្ញើរចង់ផ្ញើរ ហើយមានសិទ្ធិ ធ្វើសកម្មភាពអនុលោមតាមការសន្មត់នោះ ។ ដូច្នេះ អ្នកទទួលលែងមានសិទ្ធិ នៅពេលដែលបានដឹង ឬគួរបានដឹង តាមការដែលបានយកចិត្តទុកដាក់ក្នុងកិរិតសមរម្យ ឬបានប្រើនីតិវិធីព្រមព្រៀងណាមួយ ថាការបញ្ជូនបណ្ដាលមកពី ភាពមិនប្រក្រតីណាមួយក្នុងសារទិន្នន័យដែលបានទទួល ។

៦. អ្នកទទួលមានសិទ្ធិចាត់ទុកថាសារទិន្នន័យនិមួយៗដែលត្រូវបានទទួល ជាសារទិន្នន័យផ្សេង ហើយធ្វើសកម្មភាពអនុលោមតាមការសន្មត់នោះ លើកលែងតែវាចម្លងពីសារទិន្នន័យមួយផ្សេងទៀត ហើយអ្នកទទួលបានដឹង ឬគួរបានដឹង តាមការដែលបានយកចិត្តទុកដាក់ក្នុងកិរិតសមរម្យ ឬបានប្រើនីតិវិធីព្រមព្រៀងណាមួយ ថា សារទិន្នន័យនោះជាច្បាប់ចំលង ។

**មាត្រា ១៤ : ពេលវេលា និងទីកន្លែងនៃការបញ្ជូន និងការទទួល នូវសារទិន្នន័យ**

១. ពេលវេលានៃការបញ្ជូនសារអេឡិចត្រូនិកមួយ គឺជាពេលដែលវាចាកចេញពីប្រព័ន្ធព័ត៌មានដែលឋិតក្រោមការត្រួតពិនិត្យរបស់អ្នកផ្ញើរ ឬរបស់ភាគីដែលបញ្ជូនក្នុងនាមនៃអ្នកផ្ញើរ ឬក៏ ប្រសិនបើសារអេឡិចត្រូនិកមិនបានចាក-ចេញពីប្រព័ន្ធព័ត៌មានដែលឋិតក្រោមការត្រួតពិនិត្យរបស់អ្នកផ្ញើរ ឬរបស់ភាគីដែលផ្ញើរក្នុងនាមនៃ អ្នកផ្ញើរទេនោះ គឺជា ពេលដែលសារអេឡិចត្រូនិកនោះត្រូវបានទទួល ។

២. ពេលវេលានៃការទទួលសារអេឡិចត្រូនិកមួយ គឺជាពេលដែល វាអាចឱ្យអ្នកទទួល យកវាបាននៅអាស័យដ្ឋាន-អេឡិចត្រូនិកមួយដែលកំនត់ដោយ អ្នកទទួល ។ ពេលវេលានៃការទទួលសារអេឡិចត្រូនិកមួយ នៅអាស័យដ្ឋាន-អេឡិចត្រូនិកមួយផ្សេងទៀតរបស់អ្នកទទួល គឺជាពេលដែល វាអាចឱ្យអ្នកទទួល យកវាបាននៅអាស័យដ្ឋាននោះ



Downloaded from http://www.khmerlaws.com

ហើយ អ្នកទទួលបានដឹងថា សារអេឡិចត្រូនិកត្រូវបានផ្ញើរទៅអាស័យដ្ឋាននោះ ។ សារអេឡិចត្រូនិកមួយត្រូវសន្មត់ថា អាចឱ្យអ្នកទទួល យកវាបាន នៅពេលដែលវាទៅដល់ អាស័យដ្ឋានអេឡិចត្រូនិកនៃអ្នកទទួល ។

៣. សារអេឡិចត្រូនិកមួយ ត្រូវចាត់ទុកថាបានបញ្ជូន នៅទីកន្លែងដែលអ្នកផ្ញើរមានទីតាំងពាណិជ្ជកម្ម ហើយត្រូវចាត់ទុកថា បានទទួល នៅទីកន្លែងដែលអ្នកទទួលមានទីតាំងពាណិជ្ជកម្ម ។

៤. បទប្បញ្ញត្តិ នៃកថាខណ្ឌ២ នៃមាត្រានេះ ត្រូវអនុវត្ត បើទោះជាទីកន្លែងដែលប្រព័ន្ធព័ត៌មានទ្រទ្រង់អាស័យដ្ឋាន អាចមានទីតាំងផ្សេងពី ទីកន្លែងដែលសារអេឡិចត្រូនិកក៏ដោយ ក៏ត្រូវចាត់ទុកថាបានទទួលក្រោមបទប្បញ្ញត្តិ នៃកឋាខណ្ឌ៣ នៃមាត្រានេះដែរ ។

## ផ្នែក ៤

## អ្នកផ្តល់សេវាវិញ្ញាបនកម្ម

**មាត្រា ១៥ : ការចេញបទបញ្ជា**

១. ដោយមានការយល់ព្រមពីនាយករដ្ឋមន្ត្រី និងក្រោយពីបានប្រឹក្សាជាមួយនាយកដ្ឋាននៃក្រសួងដ៏ទៃទៀត ក្រសួង-ពាណិជ្ជកម្ម ប្រសិនបើចាំបាច់ មានសមត្ថកិច្ចធ្វើសេចក្តីព្រាង និងចេញបទបញ្ជា គ្រប់គ្រងទាំងមូល ឬមួយ ផ្នែកលើបញ្ហាខាងក្រោម :

(ក) សិទ្ធិរបស់អ្នកផ្តល់សេវាវិញ្ញាបនកម្មក្នុងការបង្កើត និងផ្តល់សេវាវិញ្ញាបនកម្ម នៅព្រះរាជាណាចក្រកម្ពុជា

(ខ) កាលកំនត់ និងលក្ខខណ្ឌ ដែលអ្នកផ្តល់សេវាវិញ្ញាបនកម្មអាចផ្តល់សេវាវិញ្ញាបនកម្ម ទៅបុគ្គលនានា

(គ) ស្តង់ដារ ដែលអ្នកផ្តល់សេវាវិញ្ញាបនកម្មត្រូវបំពេញ

(ឃ) ការទទួលស្គាល់តាមផ្លូវច្បាប់ចំពោះ អ្នកផ្តល់សេវាវិញ្ញាបនកម្មបរទេស វិញ្ញាបនបត្រទាំងឡាយចេញដោយអ្នកផ្តល់ទាំងនោះ ឬកាផ្តល់សេវាដ៏ទៃទៀត ។

២. នៅក្នុងពេលធ្វើសេចក្តីព្រាងបទបញ្ជា ក្រោមមាត្រានេះ (...) មានភារកិច្ចផ្តល់ការពិចារណាពេញលេញ និងសមស្រប ចំពោះអនុសាសន៍ គោលនយោបាយ និងស្តង់ដារ ដែលមានការគាំទ្រពីសំណាក់លេខាធិការដ្ឋានអាស៊ាន ឬក៏ពីបណ្តាអង្គានានាដែលពាក់ព័ន្ធដ៏ទៃទៀត ។

## ផ្នែក ៥

## កិច្ចរដ្ឋាភិបាល និងចម្លងការ

**មាត្រា ១៦ : ការទទួលយកសារទិន្នន័យ**

១. ទាក់ទងទៅនឹងច្បាប់ណាមួយ រាល់ស្ថាប័ននៃរដ្ឋាភិបាល ដែល :

(ក) ទទួលយកការរៀបចំឯកសារ ឬដែលតម្រូវឱ្យឯកសារត្រូវបង្កើត ឬរក្សាទុក

(ខ) ចេញការអនុញ្ញាត អាជ្ញាប័ណ្ណ ឬការយល់ព្រម ណាមួយ

(គ) ផ្តល់ វិធី ឬរបៀបនៃការទូទាត់ប្រាក់



Downloaded from http://www.khmerlaws.com

បើទោះបីជាមានបទប្បញ្ញត្តិចែងផ្ទុយពីច្បាប់នេះក៏ដោយ ក៏អាច

ក- ទទួលយកការរៀបចំឯកសារនោះ ឬការបង្កើត ឬការរក្សាទុកឯកសារនោះ ក្នុងទំរង់ជាសារទិន្នន័យ

ខ- ចេញ ការអនុញ្ញាត អាជ្ញាប័ណ្ណ ឬការយល់ព្រម ទាំងនោះ ក្នុងទំរង់ជា សារទិន្នន័យ ឬ

គ- ធ្វើការទូទាត់ប្រាក់ តាមប្រព័ន្ធអេឡិចត្រូនិក ។

២. ក្នុងគ្រប់ករណីដែល ស្ថាប័នណាមួយនៃរដ្ឋាភិបាលសំរេចបង្កើត ដំណើរការមួយក្នុង ១.ក-.ខ-.គ-. ទីភ្នាក់ងារនោះត្រូវបញ្ជាក់ពី :

(ក) របៀប និងទំហំ ដែលសារទិន្នន័យ ឬសារអេឡិចត្រូនិកនោះត្រូវបានរៀបចំ បង្កើត រក្សាទុក ឬក៏បញ្ជូន

(ខ) ប្រភេទនៃហត្ថលេខាអេឡិចត្រូនិកដែលតំរូវ ក្នុងករណីដែលសារនោះត្រូវចុះហត្ថលេខា

(គ) របៀប និងទំហំ ដែលហត្ថលេខានោះ ត្រូវបានភ្ជាប់ទៅនឹង សារទិន្នន័យ

(ឃ) ដំណើរការត្រួតពិនិត្យ និង នីតិវិធី ដែលសមរម្យដើម្បីធានាឱ្យបានគ្រប់គ្រាន់នូវ បូរណភាព សន្តិសុខ និងការសំងាត់ នៃសារទិន្នន័យ សារអេឡិចត្រូនិក ឬការទូទាត់ប្រាក់នានា និង

(ង) លក្ខណសម្បត្តិដ៏ទៃទៀត ដែលតម្រូវចំពោះសារទិន្នន័យ សារអេឡិចត្រូនិក ឬការទូទាត់ប្រាក់នានា ដែលក្នុងពេលបច្ចុប្បន្នគេកំនត់ឱ្យធ្វើជាឯកសារក្រដាស់ ។

៣. គ្មានបទប្បញ្ញត្តិណាមួយនៃច្បាប់នេះ អាចបង្ខិតបង្ខំ ស្ថាប័នណាមួយនៃរដ្ឋាភិបាល ឱ្យទទួលយក ឬចេញឯកសារណាមួយ ក្នុងទំរង់ជា សារទិន្នន័យ នោះទេ ។

## ផ្នែក ៦

## បទល្មើសប្រឆាំងនឹង ការសំងាត់ បូរណភាព ភាពអាចរកបាន នៃប្រព័ន្ធព័ត៌មាន និងទិន្នន័យកុំព្យូទ័រ

### មាត្រា ១៧ : ការចូលខុសច្បាប់

វាគឺជាបទល្មើស ចំពោះជនណាដែលចូលទាំងស្រុង ឬក្នុងផ្នែកណាមួយនៃប្រព័ន្ធព័តិមានមួយ ដោយចេតនា និងដែលបានដឹង ឬដែលមានហេតុផលអាចឱ្យគេជឿជាក់ ថាខ្លួនមិនមានការអនុញ្ញាតឱ្យចូលក្នុងប្រព័ន្ធព័តិមាននោះទេ ។

### មាត្រា ១៨ : ការរារាំងខុសច្បាប់

វាគឺជាបទល្មើស ចំពោះជនណាដែលរារាំង ដោយខុសច្បាប់ និងដោយចេតនា តាមមធ្យោបាយបច្ចេកទេស ចំពោះការបញ្ជូនដែលមិនជាសាធារណៈនៃទិន្នន័យកុំព្យូទ័រ ទៅកាន់ ឬមកពី ឬនៅក្នុង ប្រព័ន្ធព័តិមានមួយ ដោយរួមបញ្ចូលទាំងការផ្សព្វផ្សាយ តាមអេឡិចត្រូម៉ាញេទិច ចេញពីប្រព័ន្ធព័តិមានមួយដែលទ្រទ្រង់ទិន្នន័យកុំព្យូទ័រនោះ ។

### មាត្រា ១៩ : ការជ្រៀតជ្រែកចូលទិន្នន័យ

វាគឺជាបទល្មើស ចំពោះជនណាដែលបំផ្លិចបំផ្លាញ លុបបំបាត់ ធ្វើឱ្យខូច ក្លែង រាំងខ្ទប់ ឬធ្វើឱ្យទៅជាមិនអាចអានកើត ដោយចេតនា និងគ្មានសិទ្ធិ នូវទិន្នន័យកុំព្យូទ័រ នៅលើប្រព័ន្ធព័តិមាន ។



Downloaded from http://www.khmerlaws.com

**មាត្រា ២០ : ការជ្រៀតជ្រែកចូលប្រព័ន្ធ**

វាគឺជាបទល្មើស ចំពោះជនណាដែលជ្រៀតជ្រែកចូល ដោយចេតនា និងគ្មានសិទ្ធិ ក្នុងដំណើរការនៃប្រព័ន្ធព័ត៌មាន ដោយដាក់បញ្ចូល បញ្ជូន បំផ្លិចបំផ្លាញ លុបបំបាត់ ធ្វើឱ្យខូច ក្លែង រាំងខ្ទប់ ឬធ្វើឱ្យទៅជាមិនអាចអានកើត នូវទិន្នន័យកុំព្យូទ័រ ។

**មាត្រា ២១ : ការក្លែងបន្លំលើទិន្នន័យកុំព្យូទ័រ**

វាគឺជាបទល្មើស ចំពោះជនណាដែលដាក់បញ្ចូល បញ្ជូន បំផ្លិចបំផ្លាញ លុបបំបាត់ ធ្វើឱ្យខូច ក្លែង រាំងខ្ទប់ ដោយចេតនា និងគ្មានសិទ្ធិ នូវទិន្នន័យកុំព្យូទ័រ ឱ្យក្លាយទៅជាទិន្នន័យមិនយថាភូត ជាមួយនឹងបំណងចង់ឱ្យគេចាត់ទុក ឬធ្វើសកម្មភាពសំរាប់គោលបំណងតាមផ្លូវច្បាប់ ថាវាជាទិន្នន័យយថាភូត ដោយមិនគិតថាតើ ទិន្នន័យនោះអាចឱ្យគេអានបាន និងយល់បានដោយផ្ទាល់ ដែរឬអត់ ។

**មាត្រា ២២ : ការបន្លំលើកុំព្យូទ័រ**

វាគឺជាបទល្មើស ចំពោះជនណាដែល ធ្វើឱ្យបាត់ ដោយចេតនា និងគ្មានសិទ្ធិ នូវកម្មសិទ្ធិរបស់អ្នកដទៃ ដោយ :

១. ការដាក់បញ្ចូល ការក្លែង ការលុបបំបាត់ ការរាំងខ្ទប់ ទិន្នន័យកុំព្យូទ័រ

២. ការជ្រៀតជ្រែកចូលចូលក្នុងដំណើរការ នៃប្រព័ន្ធព័ត៌មាន
ជាមួយនឹងគោលបំណងក្លែងបន្លំ ឬមិនស្មោះត្រង់ ដើម្បីទទួលបានការចំនេញផ្នែកសេដ្ឋកិច្ចសំរាប់ខ្លួនឯងផ្ទាល់ ឬសំរាប់អ្នកដទៃ ។

**មាត្រា ២៣ : ការញុះញង់ ការជួយ ការជំរុញលើកទឹកចិត្ត ការសមគំនិត ឬការប៉ុនប៉ង**

១. វាគឺជាបទល្មើស ចំពោះជនណាដែល ញុះញង់ ជួយ ជំរុញលើកទឹកចិត្ត អ្នកដទៃ ឬសមគំនិតជាមួយអ្នកដទៃ ដោយចេតនា ក្នុងការប្រព្រឹតបទល្មើសណាមួយ ដែលមានចែងក្នុងមាត្រា ១៧ ដល់២២ នៃច្បាប់នេះ ។

២. វាគឺជាបទល្មើស ចំពោះជនណាដែលប៉ុនប៉ងប្រព្រឹតបទល្មើសណាមួយដែលមានចែងក្នុងមាត្រា ១៧ ដល់២២ នៃច្បាប់នេះ ។

**មាត្រា ២៤ : ទោសប្បញ្ញត្តិ**

ជនដែលត្រូវបានរកឃើញថាមានពិរុទ្ធចំពោះការប្រព្រឹត្តបទល្មើសមួយ ឬច្រើន ក្រោមបទប្បញ្ញត្តិនៃផ្នែកទី៦ នៃច្បាប់នេះ នឹងត្រូវផ្តន្ទាទោសជាប់ពន្ធនាគារ និង.ឬ ទទួលទណ្ឌកម្មពិន័យជាប្រាក់ ដោយយោងតាមតារាងខាងក្រោម :



Downloaded from http://www.khmerlaws.com